សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# កិច្ចការស្រាវជ្រាវ

# ការប្រៀបធៀបអង្គការនីតិបញ្ញត្តិប្រទេសកម្ពុជា និងអង្គការនីតិបញ្ញត្តិប្រទេសសិង្ហបុរី


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ:

-**លី សុជាតា**

-**អ៊ុក យ៉ាលីនីត**

-**លាង មុន្នីរ័ត្ន**

-**ម៉ី ពុធមករា**

-**ចូវ រតនា**

សាស្ត្រាចារ្យណែនាំ

លោក **ម៉ុក ដារ៉ា**


ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**

ជំនាញ **នីតិឯកជន** ជំនាន់ទី១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៤

**រក្សាសិទ្ធិដោយ** Khmer Famous

# ជំពូក ១

# អង្គការនីតិបញ្ញត្តិប្រទេសកម្ពុជាជំពូក ២

# អង្គការនីតិបញ្ញត្តិប្រទេសសឹង្ហបុរី



# ផ្នែកទី ១ សញ្ញាណទូទៅ

## កថាខណ្ឌទី១ ស្ថានភាពភូមិសាស្ត្រ

ប្រទេសសឹង្ហបុរី ស្ថិតនៅខាងជើងខ្សែអេក្វាទ័រចំងាយ ១៣៧គ.ម។ ប្រទេសនេះ កើតចេញពីកោះសំខាន់ ដែលមានបណ្តោយប្រវែង ៤២គ.ម និង ទទឹង ២៣គ.ម ហើយព័ទ្ធទៅដោយកោះតូចៗ ចំនួន ៦៣កោះ។ មានផ្ទៃដីសរុបប្រវែងប្រហែល ៧១៤ គ.ម$^{២}$។

ប្រទេសនេះ មានអាកាសធាតុក្តៅហើយសើម ជាមួយសីតុណ្ហភាពជាមធ្យមពេលថ្ងៃ៣១$^{0}$C និង ជាមធ្យមអប្បបរមា ២៣$^{0}$C ពេលយប់។ ប្រទេសនេះ ទទួលទឹកភ្លៀងជារៀងរាល់ឆ្នាំជាមធ្យម ២.៣ម និងមានខ្យល់មូសុងជារៀងរាល់ពីរឆ្នាំចាប់ពីខែធ្នូ ដល់មុនខែមិនា និង ពីខែមិថុនា ដល់ខែកញ្ញា។

## កថាខណ្ឌទី២ ស្ថានភាពនយោបាយ

សាធារណរដ្ឋ សឹង្ហបុរី ជាប្រទេសមួយ ដែលអនុវត្តនយោបាយមានសភាតែមួយគត់ គឺរដ្ឋសភា ដែលត្រូវបានបោះឆ្នោតជាទូទៅ ៥ឆ្នាំម្តង។ សភា និង ប្រធានាធិបតី ត្រូវចាត់ទុកថាជាអង្គការនីតិបញ្ញត្តិ។ សភា ត្រូវបានបង្កើតនៅថ្ងៃទី ០៨ ធ្នូ ១៩៦៥ ដោយការបោះឆ្នោតជាទូទៅនៅថ្ងៃទី ១៣ មេសា ១៩៦៨។ សមាជិកសភាមានចំនួន ៩៩នាក់ ដែលមាន ៨៧នាក់កើតចេញពីការបោះឆ្នោត ៣នាក់មិនមែនកើតចេញពីការបោះឆ្នោត និង ៩នាក់ត្រូវបានជ្រើសតាំង ដែលអ្នកទាំងនោះតំណាងឲ្យមុខជំនាញខុសៗគ្នា។ ការបោះឆ្នោតចុងក្រោយធ្វើនៅថ្ងៃទី ០៧ ឧសភា ២០១១ ដែលគណបក្សសកម្មភាពប្រជាជន ជាគណបក្សឈ្នះឆ្នោត ទទួលបាន ៨១កៅអី នៃ ៨៧កៅអីនៅក្នុងសភា។

## ផ្នែកទី ២ អង្គការនីតិបញ្ញត្តិ

អំណាចនៃការតាក់តែងច្បាប់នៅក្នុងប្រទេសសិង្ហបុរី ត្រូវផ្តល់ឲ្យអង្គការនីតិបញ្ញត្តិដែលមាន ប្រធានាធិបតី និង សភា។ រាល់ការជជែកវែកញែក និង ការពិភាក្សាត្រូវធ្វើឡើងជាភាសាម៉ាឡេ, អង់គ្លេស, ចិនកុកងឺ, ឬ តាមិល។

### កថាខណ្ឌទី១ សភា

សភាកើតឡើងពី:[1]

- ចំនួនសមាជិកដែលបោះឆ្នោត តំរូវឲ្យមានការបោះឆ្នោតជាទូទៅ តាមច្បាប់បង្កើតដោយអង្គការនីតិបញ្ញត្តិ
- សមាជិកផ្សេងទៀត ដែលមិនលើសពី ៩នាក់ ដែលត្រូវបានស្គាល់ថា ជាសមាជិកដែលមិនកើតចេញពីការបោះឆ្នោត ដូចដែលអង្គការនីតិបញ្ញត្តិផ្តល់ឲ្យតាមច្បាប់ទាក់ទិននឹងការបោះឆ្នោតនៅក្នុងសភា ដើម្បីប្រាកដពីការតំណាងនៅក្នុងសភានៃចំនួនសមាជិកជាអប្បបរមាពីគណបក្សនយោបាន មិនមែនជាទំរង់រដ្ឋាភិបាល
- សមាជិកផ្សេងទៀតមិនលើសពី ៩នាក់ដែលត្រូវបានតែងតាំងដោយប្រធានាធិបតី

ចំពោះសមាជិកដែលមិនកើតចេញការបោះឆ្នោត ឬ សមាជិកត្រូវបានជ្រើសតាំង មិនបោះឆ្នោតនៅក្នុងសភាទាក់ទងទៅនឹងៈ

- ស្នើឲ្យវិសោធនកម្មរដ្ឋធម្មនុញ្ញ
- ស្នើច្បាប់ផ្តល់ប្រាក់សម្រាប់រដ្ឋាភិបាល, សេចក្តីស្នើផ្តល់ប្រាក់បន្ថែមសម្រាប់រដ្ឋាភិបាល
- សេចក្តីស្នើដែលទាក់ទងនឹងការចំណាយផ្សេងៗ
- មិនបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់រដ្ឋាភិបាល
- ផ្លាស់ប្តូរប្រធានាធិបតី

ប្រសិនបើបុគ្គលដែលមិនមែនជាសមាជិកសភា ត្រូវបោះឆ្នោតទុកដូចជា អ្នកនាំពាក្យ (Speaker) ឬ អនុប្រធានអ្នកនាំពាក្យ (Deputy Speaker)។

#### ក. កូរ៉ុម

[1] មាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញប្រទេសសិង្ហបុរី អនុម័តនៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ១៩៦៥

យោងតាមចំនួនសមាជិកចូលរួម នៃចំនួនសរុបរបស់សមាជិកសភា ប្រសិនបើមានចំនួនអ្នកចូលរួម តិចជាង ១ភាគ៤ នៃចំនួនសមាជិកសរុបពេលនោះអ្នកនាំពាក្យអាចផ្អាកការប្រជុំសភា។[2]

### ខ. សម័យប្រជុំសភា

ក្នុងមួយឆ្នាំ សភាត្រូវតែមានការប្រជុំយ៉ាងហោចណាស់មួយដងជារៀងរាល់ឆ្នាំ ហើយចន្លោះពេលនៃការប្រជុំលើកទី១ និង ទី២ មិនឲ្យតិចជាង ១ខែ។

ការប្រជុំសភារបស់សភា ត្រូវធ្វើឡើងនៅកន្លែងដូចគ្នា និងពេលវេលាដូចគ្នា ហើយប្រធានាធិបតីអាចកំណត់រយៈពេលពីការប្រជុំមួយទៅការប្រជុំមួយទៀត តាមរយៈសេចក្តីប្រកាសនៅ Gazette។[3]

### គ. បុព្វសិទ្ធិរបស់សភា

អង្គការនីតិបញ្ញត្តិត្រូវមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ដើម្បីកំណត់ និងដាក់កំរិតនូវបុព្វសិទ្ធិ អភ័យឯកសិទ្ធិ ឬ អំណាចរបស់សភា។[4]

## កថាខណ្ឌទី២ អ្នកនាំពាក្យ ( Speaker )

[5]នៅពេលសភាធ្វើការជួបជុំក្រោយការបោះឆ្នោតជាទូទៅ និង មុនពេលដែលវាបន្តទៅកាន់អាជីវកម្មណាមួយផ្សេងទៀត ចាំបាច់ត្រូវមានការជ្រើសរើសអ្នកនាំពាក្យ ហើយនៅពេលណាការិយាល័យអ្នកនាំពាក្យនៅទំនេរក្រោយការរំលាយសភា នោះកិច្ចការដែលត្រូវធ្វើ គឺជ្រើសរើសអ្នកនាំពាក្យមកដាក់ក្នុងការិយាល័យ។

អ្នកនាំពាក្យអាចត្រូវបានជ្រើសរើស ដោយសភាពីមួយពេលទៅមួយពេល ទាំងក្នុងចំនោមសមាជិកសភាដែលមិនមែនជារដ្ឋមន្ត្រី ឬ អគ្គលេខាធិការសភា ឬ ក្នុងចំនោមបុគ្គលដែលមិនមែនជាសមាជិកសភា។ ក្នុងករណីបុគ្គលដែលមិនមែនជាសមាជិកសភាមិនត្រូវបានបោះឆ្នោតជាអ្នកនាំពាក្យទេ ដោយយោងតាមបញ្ញត្តិរដ្ឋធម្មនុញ្ញនេះ ព្រោះគាត់មិនសាកសមធ្វើជាសមាជិកសភា។

[២]មាត្រា ៥៦ នៃរដ្ឋធម្មនុញ្ញប្រទេសសឹង្ហបុរី

[៣]មាត្រា ៦៤ នៃរដ្ឋធម្មនុញ្ញប្រទេសសឹង្ហបុរី

[៤]មាត្រា ៦៣ នៃរដ្ឋធម្មនុញ្ញប្រទេសសឹង្ហបុរី

[៥]មាត្រា ៤០ នៃរដ្ឋធម្មនុញ្ញប្រទេសសឹង្ហបុរី

អំឡុងពេលដែលគាត់ត្រូវបានជ្រើសរើ និង មុនពេលគាត់ចូលកាន់ការងារ គាត់ត្រូវធ្វើសច្ចាប្រណិធាន។

អ្នកនាំពាក្យអាចសរសេរទៅកាន់ស្មៀនសភា និងបោះបង់ការិយាល័យរបស់ខ្លួន ហើយទុកជាមោឃៈ៖

- នៅពេលប្រជុំសភាជំបូង បន្ទាប់ពីការបោះឆ្នោត
- ករណីអ្នកនាំពាក្យបានបោះឆ្នោតចេញពីសមាជិកសភា ប្រសឹនគាត់ឈប់ធ្វើជាសមាជិកសភា ដោយមូលហេតុសុំរំលាយ ឬ ប្រសឹនគាត់ត្រូវបានជ្រើសតាំងជារដ្ឋមន្ត្រី ឬ អគ្គលេខាធិការសភា
- ករណីអ្នកនាំពាក្យបានបោះឆ្នោតជ្រើសរើសក្នុងចំនោមបុគ្គលដែលមិនមែនជាសមាជិកសភា ប្រសឹនដូចករណីខាងលើ ហើយប្រសឹនបើគាត់ត្រូវបានបោះឆ្នោតជ្រើសរើសក្នុងចំនោមឲ្យធ្វើជាសមាជិកសភា នោះគាត់ត្រូវបោះបង់សមាជិកភាពរបស់ខ្លួន។

អ្នកនាំពាក្យត្រូវទទួលប្រាក់ ដូចសមាជិកសភា ហើយបៀរវត្សរ៍នេះបានមកពីការពង្រឹងមូលនិធិ ដែលមិនត្រូវបានរំសាយក្នុងសភាគាត់កាន់កាប់នោះទេ។[6]

**ក. ជំនួយការអ្នកនាំពាក្យ**

[7]ជាធម្មតាសភាត្រូវជ្រើសរើសជំនួយការអ្នកនាំពាក្យ ២នាក់ ហើយនៅពេលដែលតំណែងណាមួយទំនេរដោយការរំលាយសភា សភាត្រូវជ្រើសរើសមនុស្សម្នាក់ភ្លាមមកបំពេញ។

ជំនួយការអ្នកនាំពាក្យអាចត្រូវបានជ្រើសរើសដោយសភា មិនថាចេញពីសភាដែលមិនមានការតែងតាំងជារដ្ឋមន្ត្រី ឬ អគ្គលេខាធិការសភា ឬ ក្នុងចំនោមបុគ្គលដែលមិនមែនជាសមាជិកសភាលើកលែងអ្នកនោះមិនសាកសមឲ្យជ្រើសរើសជាសមាជិកសភា ដោយយោងតាមរដ្ឋធម្មនុញ្ញ។

អំឡុងពេលដែលគាត់ត្រូវបានជ្រើសរើ និង មុនពេលគាត់ចូលកាន់ការងារ គាត់ត្រូវធ្វើសច្ចាប្រណិធាន។

ជំនួយការអ្នកនាំពាក្យអាចសរសេរទៅកាន់ស្មៀនសភា និងបោះបង់ការិយាល័យរបស់ខ្លួន ហើយទុកជាមោឃៈ៖

- នៅពេលប្រជុំសភាជំបូង បន្ទាប់ពីការបោះឆ្នោត

[6]មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញប្រទេសសឹង្ហបុរី
[7]មាត្រា ៤២ នៃរដ្ឋធម្មនុញ្ញប្រទេសសឹង្ហបុរី

- ករណីអ្នកនាំពាក្យបានបោះឆ្នោតចេញពីសមាជិកសភា ប្រសិនគាត់ឈប់ធ្វើជាសមាជិកសភា ដោយមូលហេតុសុំរំលាយ ឬ ប្រសិនគាត់ត្រូវបានជ្រើសតាំងជារដ្ឋមន្ត្រី ឬ អគ្គលេខាធិការសភា
- ករណីអ្នកនាំពាក្យបានបោះឆ្នោតជ្រើសរើសក្នុងចំនោមបុគ្គលដែលមិនមែនជាសមាជិកសភា ប្រសិនដូចករណីខាងលើ ហើយប្រសិនបើគាត់ត្រូវបានបោះឆ្នោតជ្រើសរើសក្នុងចំនោមឲ្យធ្វើជាសមាជិកសភា នោះគាត់ត្រូវបោះបង់សមាជិកភាពរបស់ខ្លួន។

ជំនួយការអ្នកនាំពាក្យត្រូវទទួលបានប្រាក់បៀវត្សរ៍ តាមការកំណត់របស់សភា ហើយបៀវត្សរ៍នេះ បានមកពីការពង្រឹងមូលនិធិ ដែលមិនត្រូវបានរំសាយក្នុងពេលគាត់កាន់ការនោះទេ។

**ខ. សកម្មភាពមុខងាររបស់អ្នកនាំពាក្យ**

យោងតាមរដ្ឋធម្មនុញ្ញ មុខងាររបស់អ្នកនាំពាក្យគួរតែមិនមានអ្នកណាជំនួយបានទេ ឬ ប្រសិនបើ អ្នកនាំពាក្យអវត្តមានពីសភា ឬ មិនអាចមកធ្វើការបាន គឺមានតែជំនួយការអ្នកនាំពាក្យប៉ុណ្ណោះ ឬ បើជំនួយការអ្នកនាំពាក្យអវត្តមានពីសភា ឬ មិនអាចមកធ្វើការបាន នោះសភាត្រូវជ្រើសរើសអ្នកផ្សេងឲ្យចូលកាន់ការ។[8]

## ផ្នែកទី ៣ សមាជិកសភា

### កថាខណ្ឌទី១ សមាសភាពសមាជិកសភា

[9]សមាជិកសភាត្រូវតែជាបុគ្គលដែលកើតចេញពីការបោះឆ្នោត ឬ ការតែងតាំង ដោយយោងតាមរដ្ឋធម្មនុញ្ញ ឬ ច្បាប់ដែលអនុវត្តនៅប្រទេសសឹង្ហបុរី ឬ តែងតាំងដោយខចែងនានា។

បុគ្គលដែលត្រូវបានជ្រើសរើសជាសមាជិកសភាត្រូវះ

- ពលរដ្ឋប្រទេសសឹង្ហបុរី
- មានអាយុគ្រប់ ២១ឆ្នាំ ឡើងទៅគិតដល់ថ្ងៃតែងតាំង
- បានចុះបញ្ជីបេក្ខភាព
- ស្នាក់នៅប្រទេសសឹង្ហបុរីនៅពេលជ្រើសតាំង និងស្នាក់នៅបន្តបន្ទាប់គ្នារបស់គាត់សរុបមិនតិចជាង ១០ឆ្នាំ។
- មានវិញ្ញាបនប័ត្រដែលអាចឲ្យគាត់ចូលរួមសកម្មភាពនៅក្នុងសភា, ចូលរួមផ្តល់យោបល់, ឬ មិនមែនជាអសមត្ថជន, អាចអាន និង សរសេរ យ៉ាងហោចណាស់មួយភាសា ក្នុងចំនោមភាសាអង់គ្លេស, ម៉ាឡេស៊ី, ចិនកុកងឺ, និង តាមិល។

[8]មាត្រា ៨៣ នៃរដ្ឋធម្មនុញ្ញប្រទេសសឹង្ហបុរី
[9]មាត្រា ៨៤ នៃរដ្ឋធម្មនុញ្ញប្រទេសសឹង្ហបុរី

- មិនមែនជាជនដែលមិនត្រូវបានជ្រើសរើសជាសមាជិកសភា។

**កថាខណ្ឌទី២ ការមោឃៈភាពសមាជិកភាពសភា**

ចំពោះបុគ្គលដែលមិនអាចជ្រើសរើសជាសមាជិកភាពសភាគឺ៖

- ត្រូវបានរកឃើញថា ឬ ប្រកាសថាជាជនសតិមិនប្រក្រតី
- ជាជនពុករលួយ
- កាន់ការិយាល័យរកចំណូលមួយ
- ធ្លាប់ត្រូវបានជ្រើសរើសជាសមាជិ[ក]សភា ឬ ក្នុងខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឬ ធ្លាប់ជាភ្នាក់ងារបោះឆ្នោត។
- ត្រូវបានចោទប្រកាន់ដោយតុលាការសឹង្ហបុរី ឬ ម៉ាឡេស៊ី ហើយត្រូវដាក់ពន្ធនាគារមិនតិចជាង ១ឆ្នាំ ឬ ពិន័យជាប្រាក់មិនតិចជាង ២.០០០$ (ពីរពាន់ដុល្លាអាមេរិក) ដោយកំណត់ពីការដាក់ទម្ងន់ទោសដោយតុលាការ។
- ស្ម័គ្រចិត្តសុំសញ្ជាត្តិនៅក្រៅប្រទេស (លើកលែង ប្រទេសប្រើភាសាអង់គ្លេស ឬ សាធារណរដ្ឋអៀកឡង់)។
- ជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋ

ចំពោះបុគ្គលដែលមិនត្រូវបានជ្រើសរើសក្នុងករណីធ្លាប់បានជ្រើសរើសជាសមាជិកសភា ឬ ក្នុងខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឬ ធ្លាប់ជាភ្នាក់ងារបោះឆ្នោត ឬ ត្រូវបានចោទប្រកាន់ដោយតុលាការសឹង្ហបុរី ឬ ម៉ាឡេស៊ី ត្រូវដកចេញពីបេក្ខភាព ៥ឆ្នាំ ចាប់ពីពេលដែលត្រឡប់មកវិញ។

**កថាខណ្ឌទី៣ ការកាន់មុខតំណែងរបស់សមាជិក**

រាល់សមាជិកសភាទាំងអស់ត្រូវបញ្ចប់សមាជិកភាពរបស់ខ្លួននៅពេលមានការរំលាយសភាលើកក្រោយ។

កៅអីសមាជិកសភានឹងទំនេរនៅពេលដែល៖

- ឈប់ធ្វើជាប្រជាពលរដ្ឋរបស់សឹង្ហបុរី
- លាឈប់ពីគណបក្សនយោបាយដែលគាត់ឈរឈ្មោះពេលបោះឆ្នោត
- តាមរយៈលិខិតរបស់គាត់ទៅកាន់អ្នកនាំពាក្យ ថាគាត់សុំឈប់ពីសភា
- អវត្តមានក្នុងកំឡុងពេល ២ខែដំបូងនៃការជ្រើសតាំង ដោយមិនមានការជូនដំណឹងដល់អ្នកនាំពាក្យ។
- ការមោឃៈភាពសមាជិកភាពរបស់សភា

- ប្រសិនបើគាត់ចាកចេញពីសភា ដើម្បីទាមទារអំណាច
- ផុតអាណត្តិ

សមាជិកមិនទាន់ស្របច្បាប់របស់សភា ក៏ត្រូវលះបង់កៅអីរបស់ខ្លួនដូចសមាជិកខាងលើដែរ ប្រសិនបើគាត់ត្រូវបានជ្រើសរើសជាសមាជិក។

សមាជិកសភាដែលបានប្រជុំរួចក៏ត្រូវរំសាយដូចសមាជិករូបខាងលើដែរ ក្នុងករណីៈ

- គាត់ឈរជាបេក្ខភាពគណបក្សនយោបាយណាមួយក្នុងពេលបោះឆ្នោត
- មិនមែនជាសមាជិកដោយឈរជាបេក្ខភាពគណបក្សនយោបាយណាមួយក្នុងពេលបោះឆ្នោត គាត់នឹងត្រូវបានរើសជាសមាជិករដ្ឋធម្មនុញ្ញ

គ្រប់បុគ្គលដែលមានកៅអីនៅក្នុងសភា ដែលបានបោះបង់កៅអី អាចត្រូវជ្រើសតាំងជាថ្មីជាសមាជិកសភា។

## ផ្នែកទី ៤ មុខងាររបស់សភា

### កថាខណ្ឌទី១ ការបង្កើតច្បាប់

មុខងារសំខាន់របស់សភា គឺការបង្កើតច្បាប់សំរាប់ប្រទេស។ មុនពេលច្បាប់ត្រូវបានអនុម័តត្រូវដាក់សេចក្តីព្រាងច្បាប់ទៅសភា ដែលដាក់ជូនដោយរដ្ឋមន្ត្រីក្នុងនាមជារដ្ឋាភិបាល។ ទោះជាយ៉ាងណា គ្រប់សមាជិករបស់សភា អាចដាក់សេចក្តីស្នើបាន ហើយរាល់សេចក្តីស្នើត្រូវឆ្លងកាត់ការពិនិត្យចំនួន ៣ដង នៅក្នុងសភា និង ការយល់ព្រមពីប្រធានាធិបតីដើម្បីក្លាយជាច្បាប់។ លើកទី១គ្មានការតវ៉ាអ្វីទាំងអស់ ដោយគ្រាន់តែដាក់សំណើរទៅរដ្ឋសភា ថាអានជាលើកទី២ ដែលជាដំណាក់សមាជិកសភាមានឱកាសតវ៉ាលើគោលការណ៍សេចក្តីស្នើ។ ករណី សមាជិកសភាពិនិត្យឃើញថា សេចក្តីស្នើមានសារៈប្រយោជន៍ចំពោះប្រទេស គាត់នឹងបោះឆ្នោតឲ្យបន្ត។ ហើយបញ្ជូនទៅឲ្យគណៈកម្មាការសភាត្រួតពិនិត្យបន្ត។ ករណី សមាជិកសភាណាមិនពេញចិត្តនូវឃ្លាណាមួយនៃសេចក្តីស្នើ អាចស្នើសុំឲ្យធ្វើការកែប្រែម្តងទៀត។ លើកទី៣ គាត់ត្រូវធ្វើរបាយការណ៍អំពីការមិនពេញចិត្តមុនពេលសេចក្តីស្នើត្រូវអនុម័ត។

### កថាខណ្ឌទី២ ការត្រួតពិនិត្យសកម្មភាពក្រសួង

នៅពេលចាប់ផ្តើមការប្រជុំសភា មានការចំណាយពេល ១ម៉ោងកន្លះសំរាប់សាកសួរ ដែលនេះជាឱកាសសំរាប់សមាជិកសភាលើកឡើងនូវសំណួរអំពីបញ្ហាការទទួលខុសត្រូវរបស់ក្រសួងនី

មួយៗ។ តាមរយៈការសួរនេះ សភាបង្កើតឲ្យមានរដ្ឋាភិបាលទទួលខុសត្រូវចំពោះសកម្មភាពនេះ និងអនុញ្ញាតឲ្យស្តាប់ជាសាធារណៈ និងបញ្ចេញមតិ ដើម្បីរកការសំរេចចិត្ត។

**កថាខណ្ឌទី៣ ការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ**

សភាអនុវត្តទៅលើថវិការជារៀងរាល់ឆ្នាំ ដែលតែងតែប្រព្រឹត្តិទៅនៅចុងខែកុម្ភៈ ឬ ដើមខែមិនា។ ក្រសួងហិរញ្ញវត្ថុ នឹងពិនិត្យឡើងវិញនូវការអនុវត្តសេដ្ឋកិច្ចនៅឆ្នាំមុន និង ប្រកាសទៅលើសេចក្តីព្រាងច្បាប់ទាក់ទងនឹងសេដ្ឋកិច្ច រួមមាន ពន្ធនានា។

## ផ្នែកទី ៥ ការបញ្ចប់សម័យប្រជុំ និង ការរំលាយសភា

នៅពេលណាក៏ដោយ ប្រធានាធិបតី អាចពន្យាពេលនៃការប្រជុំសភាបាន ដោយធ្វើសេចក្តីប្រកាសនៅ Gazette។

នៅពេលណាក៏ដោយ បើមុខតំណែងរបស់នាយករដ្ឋមន្ត្រីទំនេរ ប្រធានាធិបតីត្រូវរំលាយសភាឲ្យបានឆាប់តាមដែលគាត់ចង់បាន ដោយធ្វើសេចក្តីប្រកាសនៅ Gazette ដោយចាត់វិធានការយ៉ាងប្រុងប្រយ័ត្ន ដែលជារយៈពេលទទួលខុសត្រូវមួយបានកន្លងផុតទៅ ចាប់តាំងពីតំណែងរបស់នាយករដ្ឋមន្ត្រីទាំងនោះ ត្រូវបានទំនេរចុងក្រោយបំផុត ហើយដែលមិនមានសមាជិករបស់សភាម្នាក់ ប្រហែលជាបង្គាប់បញ្ជានូវសេចក្តីទុកចិត្តរបស់មតិភាគច្រើននៃសមាជិកសភាទាំងអស់។

នៅពេលណាក៏ដោយ ប្រធានាធិបតីអាចរំលាយសភាបាន ដោយសេចក្តីប្រកាសនៅ Gazette ប្រសិនបើគាត់ត្រូវបានស្នើឲ្យរំលាយសភាដោយនាយករដ្ឋមន្ត្រី ប៉ុន្តែប្រធានាធិបតីមិនតំរូវឲ្យគោរពទៅតាមការស្នើសុំរបស់នាយករដ្ឋមន្ត្រី លុះត្រាតែគាត់យល់ព្រមទៅនឹងសំណើនោះដែរ ដោយការស្នើសុំរបស់នាយករដ្ឋមន្ត្រីនោះ បង្គាប់បញ្ជានូវសេចក្តីទុកចិត្តរបស់មតិភាគច្រើន នៃសមាជិករបស់សភាទាំងអស់។

សភា នឹងបន្តរយៈពេល ៥ឆ្នាំ គិតចាប់ពីថ្ងៃចូលដំបូងរបស់ខ្លួន ប្រសិនបើត្រូវបានរំលាយ។

ផ្ទុយមកវិញ ការបោះឆ្នោតជាទូទៅនឹងមាននៅពេលជាក់លាក់មួយ នៅរយៈពេល ៣ខែ បន្ទាប់ពីរៀងរាល់ការរំលាយសភា ដោយប្រធានាធិបតី តាមសេចក្តីប្រកាសនៅ Gazette។